**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ៣២៧៣ អយក.ជាវ**

ថ្ងៃពុធ ៣រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៦

**សូមគោរពជូន**
**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា កែសម្រួលអង្គភាពថវិកាថ្នាក់រដ្ឋបាលកណ្តាលសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២៧ តទៅ។

**យោង ៖** លិខិតលេខ៣៣៨៦ សហវ.ល.ស.អថ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា៖ ៖ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡាមានអង្គភាពថវិកាសរុបចំនួន៥៩អង្គភាព (រដ្ឋបាលកណ្តាលចំនួន៣៤និងមន្ទីររាជធានី ខេត្តចំនួន២៥)និងកម្មវិធីចំនួន៥ ព្រមទាំងបានវិភាជថវិកាជូនដល់គ្រប់អង្គភាពថវិកា ក្នុងគោលបំណងបង្កើនការទទួលខុសត្រូវខ្ពស់ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។ ដោយឡែក ក្នុងឆ្នាំ២០២៦ ក្រសួងបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២៧ តទៅ តាមលិខិតលេខ៣៣៨៦ សហវ.ល.ស.អថ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ ដោយបានធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធអង្គភាពថវិកាកម្មវិធីឡើងវិញ ជាពិសេសពាក់ព័ន្ធនឹងការបង្រួមអង្គភាពថវិកា ផ្ទេរអង្គភាពថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយផ្សេង និងបង្កើតអង្គភាពថវិកាថ្មី។

ក្រសួងបានពិនិត្យឃើញថា តាមស្មារតីនៃលិខិតលេខ៨៥១៤ សហវ.ល.ស.អថ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធអង្គភាពថវិកា ដោយកំណត់អង្គភាពថវិកានៅកម្រិតអគ្គនាយកដ្ឋានឬប្រហាក់ប្រហែល និងធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការអនុវត្តថវិការបស់អង្គភាពមួយចំនួន ដែលមានបទពិសោធន៍គ្រប់គ្រាន់ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ស្របតាមគោលការណ៍ណែនាំ ស្តីពីការបង្កើតអង្គភាពថវិកា។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវស្នើសុំអនុញ្ញាតជាគោលការណ៍ពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបានធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធអង្គភាពថវិកាឡើងវិញសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០២៧ ដូចខាងក្រោម៖



អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

១-ស្នើសុំបង្រួមអង្គភាពថវិកា៖

សម្រាប់ការអនុវត្តថវិកាក្នុងឆ្នាំ២០២៦ មានអង្គភាពថវិកាសរុបចំនួន៥៩អង្គភាពដែលមានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន១៧និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន៤២អង្គភាព ដែលមានគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន៧ ហើយសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២៧ ក្រសួងសូមស្នើលុបអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន១១អង្គភាព ដោយបង្កើតអង្គភាពថវិកាថ្មីក្នុងកម្រិតអគ្គនាយកដ្ឋានឬអគ្គាធិការដ្ឋាន ឱ្យស្របនឹងលិខិតលេខ៨៥១៤ សហវ.ល.ស.អថ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១.១-កម្មវិធីទី១៖សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាក្រោមចំណុះចំនួន៨អង្គភាព។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ ក្រសួងសូមស្នើសុំលុបអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន៨ ដែលស្ថិតនៅកម្រិតនាយកដ្ឋាននិងអគ្គនាយកដ្ឋាននៃកម្មវិធីទី១ រួមមាន៖

-អង្គភាពថវិកានាយកដ្ឋានអប់រំកុមារតូច

-អង្គភាពថវិកានាយកដ្ឋានបឋមសិក្សា

-អង្គភាពថវិកានាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

-អង្គភាពថវិកានាយកដ្ឋានអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន

-អង្គភាពថវិកានាយកដ្ឋានសុខភាពសិក្សា

-អង្គភាពថវិកានាយកដ្ឋានតម្រង់ទិសនិងវិជ្ជាជីវៈ

-អង្គភាពថវិកាអគ្គនាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹត្យការ

-អង្គភាពថវិកានាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

១.២-កម្មវិធីទី២៖សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាក្រោមចំណុះចំនួន១៨អង្គភាព។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ ក្រសួងសូមស្នើលុបអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន៤ ដែលស្ថិតនៅកម្រិតនាយកដ្ឋានចំនួន២និងគ្រឹះស្ថានឧត្តមសិក្សាចំនួន២ រួមមាន៖

-អង្គភាពថវិកានាយកដ្ឋានគ្រប់គ្រងឧត្តមសិក្សា

-អង្គភាពថវិកានាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍

-អង្គភាពថវិកាសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

-អង្គភាពថវិកាសាកលវិទ្យាល័យក្រចេះ។

១.៣-កម្មវិធីទី៥៖សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាក្រោមចំណុះចំនួន៥អង្គភាព។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ ក្រសួងសូមស្នើសុំលុបអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន២ ដែលស្ថិតនៅកម្រិតនាយកដ្ឋាននៃកម្មវិធីទី៥ រួមមាន៖

-អង្គភាពថវិកានាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ

-អង្គភាពថវិកានាយកដ្ឋានអធិការកិច្ចនិងបណ្តឹងតវ៉ា។

២-ផ្ទេរអង្គភាពថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយ៖

កម្មវិធីទី២៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាចំនួន១៨។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ ក្រសួងសូមស្នើផ្ទេរអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន២និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១ ដោយផ្ទេរទៅកម្មវិធីទី៥ រួមមាន៖

-អង្គភាពអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ៖

- អង្គភាពថវិកាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- អង្គភាពថវិកាវិទ្យាស្ថានគរុកោសល្យបាត់ដំបង

-អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ៖

- អង្គភាពថវិកាវិទ្យាស្ថានជាតិអប់រំ។

៣-ស្ថានភាពនៃការកែសម្រួលអង្គភាពថវិកា៖

៣.១-កម្មវិធីទី១៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាចំនួន៨។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ មានអង្គភាពថវិកាចំនួន១ ដោយបង្កើតអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញថ្មីចំនួន១ គឺអគ្គនាយកដ្ឋានអប់រំ។

៣.២-កម្មវិធីទី២៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាចំនួន១៨។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ មានអង្គភាពថវិកាចំនួន១២(អាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន១និងអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១១) ដោយបង្កើតអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញថ្មីចំនួន១ គឺអគ្គនាយកដ្ឋានឧត្តមសិក្សា។

៣.៣-កម្មវិធីទី៣៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន២ ហើយសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ គឺចំនួន២ រក្សាដដែល។

៣.៤-កម្មវិធីទី៤៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១ ហើយសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ គឺចំនួន១ រក្សាដដែល។

៣.៥-កម្មវិធីទី៥៖ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ មានអង្គភាពថវិកាចំនួន៥(អាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន២និងអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន៣)។ ដោយឡែក សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៧ មានអង្គភាពថវិកាចំនួន៧(អាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន៣និងអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន៤) ដោយបង្កើតអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញថ្មីចំនួន១ គឺអគ្គាធិការដ្ឋាន។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ ពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកែសម្រួលអង្គភាពថវិកានៅថ្នាក់កណ្ដាលពីចំនួន៣៤ មកនៅត្រឹម២៣វិញ សរុបចំនួន៤៨អង្គភាព ដើម្បីឱ្យស្របជាមួយនឹងការកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីថ្មី ត្រូវអនុវត្តចាប់ពីឆ្នាំ២០២៧ តទៅ ក្នុងនោះ៖

១-រដ្ឋបាលកណ្តាលចំនួន២៣អង្គភាពថវិកា រួមមាន៖

-អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន៦អង្គភាព

-អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១៧អង្គភាព( គ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន៧ )

២-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន២៥អង្គភាព ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ពេញលេញ ដោយរក្សាដដែល។

*.សូមជូនភ្ជាប់នូវ៖ តារាងបញ្ជីឈ្មោះអង្គភាពថវិកាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២៧ តទៅ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំ សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យលទ្ធភាពឱ្យក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាលសម្រាប់ការអនុវត្តក្នុងឆ្នាំ២០២៧ ខាងមុខ ដោយសេចក្តីអនុគ្រោះ។

សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋាន

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានហិរញ្ញវត្ថុ

# តារាងបញ្ជីឈ្មោះអង្គភាពថវិកាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០២៧

| ឈ្មោះអង្គភាពថវិកា | | ផ្សេងៗ |
|---|---|---|
| **កម្មវិធីទី១៖** | **ការអប់រំកុមារតូចនិងចំណេះទូទៅ** | |
| ១ | អគ្គនាយកដ្ឋានអប់រំ | ផ្ទេរសិទ្ធិមិនពេញលេញ |
| **កម្មវិធីទី២៖** | **ការអប់រំឧត្តមសិក្សា** | |
| ១ | អគ្គនាយកដ្ឋានឧត្តមសិក្សា | ផ្ទេរសិទ្ធិមិនពេញលេញ |
| ២ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ផ្ទេរសិទ្ធិពេញលេញ |
| ៣ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៤ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៥ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៦ | សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៧ | សាកលវិទ្យាល័យស្វាយរៀង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៨ | សាកលវិទ្យាល័យជាតិបាត់ដំបង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៩ | សាកលវិទ្យាល័យជាតិមានជ័យ | ផ្ទេរសិទ្ធិពេញលេញ |
| ១០ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ផ្ទេរសិទ្ធិពេញលេញ |
| ១១ | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ផ្ទេរសិទ្ធិពេញលេញ |
| ១២ | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ផ្ទេរសិទ្ធិពេញលេញ |
| **កម្មវិធីទី៣៖** | **ការអប់រំកាយ និងកីឡា** | |
| ១ | អគ្គនាយកដ្ឋានកីឡា | ផ្ទេរសិទ្ធិពេញលេញ |
| ២ | ពហុកីឡដ្ឋានជាតិ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| **កម្មវិធីទី៤៖** | **ការអភិវឌ្ឍយុវជន** | |
| ១ | អគ្គនាយកដ្ឋានយុវជន | ផ្ទេរសិទ្ធិពេញលេញ |

| ឈ្មោះអង្គភាពថវិកា | | ផ្សេងៗ |
|---|---|---|
| **កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | | |
| ១ | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | ផ្ទេរសិទ្ធិពេញលេញ |
| ២ | អគ្គលេខាធិការដ្ឋាន | ផ្ទេរសិទ្ធិពេញលេញ |
| ៣ | អគ្គាធិការដ្ឋាន | ផ្ទេរសិទ្ធិមិនពេញលេញ |
| ៤ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ផ្ទេរសិទ្ធិមិនពេញលេញ |
| ៥ | វិទ្យាស្ថានជាតិអប់រំ | ផ្ទេរសិទ្ធិពេញលេញ |
| ៦ | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | ផ្ទេរសិទ្ធិមិនពេញលេញ |
| ៧ | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | ផ្ទេរសិទ្ធិមិនពេញលេញ |
| **មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត** | | |
| ១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ | ផ្ទេរសិទ្ធិពេញលេញ |
| ២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង | ផ្ទេរសិទ្ធិពេញលេញ |
| ៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម | ផ្ទេរសិទ្ធិពេញលេញ |
| ៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង | ផ្ទេរសិទ្ធិពេញលេញ |
| ៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ | ផ្ទេរសិទ្ធិពេញលេញ |
| ៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ | ផ្ទេរសិទ្ធិពេញលេញ |
| ៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត | ផ្ទេរសិទ្ធិពេញលេញ |
| ៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល | ផ្ទេរសិទ្ធិពេញលេញ |
| ៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកោះកុង | ផ្ទេរសិទ្ធិពេញលេញ |
| ១០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ | ផ្ទេរសិទ្ធិពេញលេញ |
| ១១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តមណ្ឌលគិរី | ផ្ទេរសិទ្ធិពេញលេញ |
| ១២ | មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ | ផ្ទេរសិទ្ធិពេញលេញ |
| ១៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះវិហារ | ផ្ទេរសិទ្ធិពេញលេញ |
| ១៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង | ផ្ទេរសិទ្ធិពេញលេញ |
| ១៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តពោធិ៍សាត់ | ផ្ទេរសិទ្ធិពេញលេញ |
| ១៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី | ផ្ទេរសិទ្ធិពេញលេញ |
| ១៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប | ផ្ទេរសិទ្ធិពេញលេញ |
| ១៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះសីហនុ | ផ្ទេរសិទ្ធិពេញលេញ |
| ១៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង | ផ្ទេរសិទ្ធិពេញលេញ |

| ឈ្មោះអង្គភាពថវិកា | | ផ្សេងៗ |
|---|---|---|
| ២០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង | ផ្ទេរសិទ្ធិពេញលេញ |
| ២១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ | ផ្ទេរសិទ្ធិពេញលេញ |
| ២២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ | ផ្ទេរសិទ្ធិពេញលេញ |
| ២៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកែប | ផ្ទេរសិទ្ធិពេញលេញ |
| ២៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តប៉ៃលិន | ផ្ទេរសិទ្ធិពេញលេញ |
| ២៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ | ផ្ទេរសិទ្ធិពេញលេញ |

ថ្ងៃសុក្រ ៦កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦
**អ្នករៀបចំ**

នួន ម៉ៅឆេ

**បានឃើញនិងពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋាន**

ជា គឹម

**បានឃើញនិងឯកភាព**
**អគ្គលេខាធិការ**

ឆេព គិមយ៉ាវិន្ទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...........សហវ.

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការដាក់ឱ្យអនុវត្តអង្គភាពថវិកា

**ឧបនាយករដ្ឋមន្ត្រី** **ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៩២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកានិងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

## សម្រេច

**ប្រការ១.**_

ទទួលស្គាល់និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៤៨ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.**_

ប្រកាសអន្តរក្រសួងលេខ ៧៧៧ សហវ.ប្រក.អថ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.**_

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីខែមករា ឆ្នាំ២០២៧ តទៅ។

ថ្ងៃសុក្រ ៤រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គលេខាធិការដ្ឋាន**
**នាយកដ្ឋានហិរញ្ញវត្ថុ**

## ឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ [illegible] ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៦
ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

| **ឈ្មោះអង្គភាពថវិកា** | | **ផ្សេងៗ** |
|---|---|---|
| **ក. អង្គភាពថវិការណសាម័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល** | | |
| កម្មវិធីទី២ | ការអប់រំឧត្តមសិក្សា | |
| ១ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | |
| ២ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៣ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៤ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៥ | សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៦ | សាកលវិទ្យាល័យស្វាយរៀង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៧ | សាកលវិទ្យាល័យជាតិបាត់ដំបង | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| ៨ | សាកលវិទ្យាល័យជាតិមានជ័យ | |
| ៩ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | |
| ១០ | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | |
| ១១ | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | |
| កម្មវិធីទី៣ | ការអប់រំកាយ និងកីឡា | |
| ១ | អគ្គនាយកដ្ឋានកីឡា | |
| ២ | ពហុកីឡដ្ឋានជាតិ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| កម្មវិធីទី៤ | ការអភិវឌ្ឍយុវជន | |
| ១ | អគ្គនាយកដ្ឋានយុវជន | |
| កម្មវិធីទី៥ | ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | |
| ១ | អគ្គលេខាធិការដ្ឋាន | |
| ២ | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | |
| ៣ | វិទ្យាស្ថានជាតិអប់រំ | |
| **ខ. អង្គភាពថវិការណសាម័កផ្ទេរសិទ្ធិមិនពេញលេញនៅថ្នាក់កណ្តាល** | | |
| កម្មវិធីទី១ | ការអប់រំកុមារតូចនិងចំណេះទូទៅ | |
| ១ | អគ្គនាយកដ្ឋានអប់រំ | |
| កម្មវិធីទី២ | ការអប់រំឧត្តមសិក្សា | |
| ១ | អគ្គនាយកដ្ឋានឧត្តមសិក្សា | |
| កម្មវិធីទី៥ | ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | |

| | | |
|---|---|---|
| ១ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | |
| ២ | អគ្គាធិការដ្ឋាន | |
| ៣ | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | |
| ៤ | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | |
| **គ. អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅមន្ទីរជំនាញ រាជធានី-ខេត្ត** | | |
| ១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ | |
| ២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង | |
| ៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម | |
| ៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង | |
| ៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ | |
| ៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ | |
| ៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត | |
| ៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល | |
| ៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកោះកុង | |
| ១០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ | |
| ១១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តមណ្ឌលគិរី | |
| ១២ | មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ | |
| ១៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះវិហារ | |
| ១៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង | |
| ១៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តពោធិ៍សាត់ | |
| ១៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី | |
| ១៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប | |
| ១៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះសីហនុ | |
| ១៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង | |
| ២០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង | |
| ២១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ | |
| ២២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ | |
| ២៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកែប | |
| ២៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តប៉ៃលិន | |
| ២៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ | |

ថ្ងៃ សុក្រ ៤ រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**